# ភាពអង់អាចនៃធុរកិច្ចប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា: ដំណើរឆ្ពោះទៅរកស្តង់ដារកាតព្វកិច្ចជាសកលលើដំណើការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និង បរិស្ថាន

### រាជធានីភ្នំពេញ, សណ្ឋាគារ Raffles Hotel Le Royal ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០២៤

## សារតា

ទិដ្ឋភាពបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប និងសកលលោកកំពុងឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់មួយជាមួយនឹងការណែនាំនៃបទប្បញ្ញត្តិជាកាតព្វកិច្ចស្តីពីដំណើការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន(mHREDD)។ បទប្បញ្ញត្តិទាំងនេះតម្រូវឱ្យអាជីវកម្មទទួលខុសត្រូវចំពោះផលប៉ះពាល់របស់ពួកគេទៅលើមនុស្ស និងបរិស្ថានទូទាំងដំណើរការជាសកល និងខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។

ខណៈពេលដែលបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប ស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDDD) នឹងតំណាងឱ្យជាតុផ្សំសំខាន់នៃការផ្លាស់ប្តូរនេះ ហើយវានឹងរួមចំណែកដល់ការប្រតិបត្តិការសកម្មភាពក្នុងក្របខណ្ឌសហភាពអឺរ៉ុប វាគឺជាផ្នែកមួយនៃនិន្នាការសកលដ៏ទូលំទូលាយឆ្ពោះទៅរកការពង្រឹងអនុលោមភាពជាកាតព្វកិច្ចដើម្បីការពារសិទ្ធិមនុស្ស និង បរិស្ថាន។ ក្របខណ្ឌវិវត្តន៍នេះគឺមានភាពចាំបាច់សម្រាប់ក្រុមហ៊ុនជុំវិញពិភពលោក រួមទាំងក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា ដែលក្រុមហ៊ុនផលិតក្នុងស្រុកក្នុងវិស័យនានាដូចជាវាយនភណ្ឌ កសិកម្ម និងអេឡិចត្រូនិចត្រូវបានរួមបញ្ចូលយ៉ាងជ្រៅទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់សកល។

ជាមួយនឹងច្បាប់របស់ប្រទេសអាល្លឺម៉ង់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ បានចូលជាធរមានយ៉ាងពេញលេញ និងការអនុម័តជាផ្លូវការនៃសេចក្តីណែនាំរបស់សហភាពអឺរ៉ុប ស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (EU CSDDD) ដែលរំពឹងថានឹងចេញជាលទ្ធផលនៅចុងខែមេសា ហើយតំបន់ផ្សេងទៀតក៏បង្កើនក្របខណ្ឌបទប្បញ្ញត្តិរបស់ពួកគេផងដែរ វាមានសារៈសំខាន់ណាស់សម្រាប់ធុរកិច្ច និងស្ថាប័នរដ្ឋាភិបាលកម្ពុជាក្នុងការចាប់យកការអភិវឌ្ឍន៍ទាំងនេះ។ ការយល់ដឹង និងការសម្របខ្លួនទៅនឹងតម្រូវការជាកាតព្វកិច្ចចំពោះដំណើការត្រួតពិនិត្យភាពត្រឹមត្រូវ ក៏ដូចជាការផ្លាស់ប្តូរតម្រូវការរបស់អ្នកប្រើប្រាស់សម្រាប់ការអនុវត្តប្រកបដោយក្រមសីលធម៌ មិនមែនគ្រាន់តែជាការរក្សាលទ្ធភាពទទួលបានទីផ្សារប៉ុណ្ណោះទេ ប៉ុន្តែអំពីការឈានមុខគេក្នុងការអនុវត្តធុរកិច្ចប្រកបដោយនិរន្តរភាព ហើយ រក្សាបាននូវខ្សែចង្វាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព និងភាពធន់។

កម្មវិធីនេះមានគោលបំណងពិភាក្សាអំពីគោលការណ៍នៃស្តង់ដារជាសកលទាំងនេះ ដូចជាគោលការណ៍នៃការទទួលខុសត្រូវរួម និងផលប៉ះពាល់ដែលអាចកើតមានចំពោះឧស្សាហកម្មសំខាន់ៗរបស់កម្ពុជា។ តាមរយៈការជំរុញការយល់ដឹងស៊ីជម្រៅ និងការសម្របខ្លួនយ៉ាងសកម្មក្នុងចំណោមភាគីពាក់ព័ន្ធ កម្ពុជាអាចលើកកម្ពស់ការប្រកួតប្រជែងរបស់ខ្លួន និងធានាបាននូវអនុលោមភាព ដោយធានាបាននូវអនាគតប្រកបដោយនិរន្តរភាពសម្រាប់ឧស្សាហកម្មរបស់ខ្លួន ចំពេលមានកំណើនតម្រូវការតឹងរ៉ឹងជាងមុន។

## គោលបំណង

កម្មវិធីនេះ ប្រមូលផ្តុំតួអង្គសំខាន់ៗពីរដ្ឋាភិបាល វិស័យនាំចេញសំខាន់ៗ រួមមាន វាយនភ័ណ្ឌ កសិកម្ម និងអេឡិចត្រូនិច និងសង្គមស៊ីវិលក្នុងគោលបំណង៖

- ស្វែងយល់ពីស្តង់ដារកាតព្វកិច្ចជាសកលស្តីពីដំណើការត្រួតពិនិត្យភាពត្រឹមត្រូវ ៖ ពិភាក្សាអំពីគោលការណ៍នៃធុរកិច្ចប្រកបដោយទំនួលខុសត្រូវ និងបទប្បញ្ញត្តិអន្តរជាតិ (ដូចជាបទប្បញ្ញត្តិនៅក្នុងសហភាពអឺរ៉ុប និងបទប្បញ្ញត្តិស្រដៀងគ្នាផ្សេងទៀត) និងផលប៉ះពាល់ដែលអាចកើតមានសម្រាប់ធុរកិច្ចកម្ពុជាក្នុងវិស័យវាយនភណ្ឌ កសិកម្ម និងអេឡិចត្រូនិច។
- ផ្លាស់ប្តូរចំណេះដឹងលើវិស័យទាំងមូល៖ ចែករំលែកការយល់ដឹង និងការអនុវត្តល្អបំផុតលើការប្រកបអាជីវកម្មដោយទំនួលខុសត្រូវ និងការសម្របខ្លួនទៅនឹងកាព្វកិច្ចនៃការត្រួតពិនិត្យភាពត្រឹមត្រូវ ដោយសង្កត់ធ្ងន់លើវិធីសាស្រ្តជាក់ស្តែងសម្រាប់ឧស្សាហកម្មកម្ពុជា។
- ពង្រឹងនូវកិច្ចសហការ៖ ពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់តាមខ្សែចង្វាក់តម្លៃ ព្រមទាំងរៀបចំ ផ្តល់ដល់ពួកនូវយុទ្ធសាស្រ្ត និងឧបករណ៍ដែលត្រូវការដើម្បីអនុលោមតាមស្តង់ដារចាំបាច់ និងរក្សាការប្រកួតប្រជែងនៅក្នុងទីផ្សារអន្តរជាតិ។

ចូលរួមជាមួយយើងសម្រាប់ការពិភាក្សាដ៏សំខាន់នេះ ហើយត្រៀមខ្លួនជាស្រេចជាមួយចំណេះដឹងថ្មីៗ ឆ្ពោះទៅរកទិដ្ឋភាពថ្មីនៃការប្រកបអាជីវកម្មដោយនិរន្តរភាព!សូមចុះឈ្មោះរហូតដល់ថ្ងៃទី ០៣ខែឧសភា ឆ្នាំ២០២៤តាមរយៈ តំណភ្ជាប់នេះ។

## របៀបវារៈ

| ម៉ោង | កម្មវិធី | វាគ្មិន |
|---|---|---|
| ៨:៣០-៩:០០ | **ចុះឈ្មោះ** | |
| ៩:០០-៩:០៥ | **សុន្ទរកថាស្វាគមន៍** | Martin Brisson, នាយកប្រតិបត្តិ Eurocham Cambodia |
| ៩:០៥-៩:១៥ | **សុន្ទរកថាបើក** - តួនាទីរបស់ប្រទេសអាឡឺម៉ង់ក្នុងដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) | Jost Kadel, អនុប្រធានទទួលបន្ទុកបេសកកម្ម និងជាប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ស្ថានទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ |
| ៩:១៥-៩:២៥ | **សុន្ទរកថាបើក** - សារៈសំខាន់នៃធុរកិច្ចប្រកដោយទំនួលខុស សម្រាប់សេដ្ឋកិច្ចកម្ពុជា។ | H.E. Lim Suyhong, អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | |
|---|---|---|
| ៩:២៥-១០:១០ | **បើកបង្ហាញហេតុផលនៃបទបញ្ញត្តិជាកាតព្វកិច្ច**ស្តីពីដំណើការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន៖ កិច្ចសន្ទនាស្តីពីការអនុវត្ត ការរៀនសូត្រ និងអនាគតខាងមុខ។ | Koen Everaert, លេខាទី១នៃប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា<br><br>Reinhard Junker, ប្រធានស្តីទីនៃនាយកដ្ឋាន បំលាស់ប្តូរ នៃខ្សែចង្វាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព របស់ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍របស់សហព័ន្ធអាល្លឺម៉ង់ ( BMZ ) |
| ១០:១០-១០:៣០ | **សម្រាក** | |
| ១០:៣០-១១:១០ | **ការចែករំលែកការយល់ដឹងពីថ្នាក់មូលដ្ឋាន**<br><br>**ត្រៀមរៀបចំសម្រាប់ការផ្លាស់ប្តូរ៖** ការយល់ដឹង និងការរុករកផលប៉ះពាល់ដែលអាចកើតមានលើខ្សែចង្វាក់ផ្គត់ផ្គង់នៅកម្ពុជា។<br><br>**ការផ្តល់ភាពអង់អាចសម្រាប់ការផ្លាស់ប្តូរ៖** ការចែករំលែកការអនុវត្តល្អសម្រាប់ធុរកិច្ចប្រកបដោយទំនួលខុសត្រូវពីវិស័យវាយនភណ្ឌ និងវិស័យកសិកម្ម។ | Archana Kotecha, ស្ថាបនិក និងជានាយកប្រតិបត្តិ គម្រោងRemedy<br><br>Mr. Samaun Tiv, ប្រធានផ្នែក compliance, Dewhirst (Cambodia) Co., Ltd.<br><br>តំណាងពីក្រុមហ៊ុនកសិកម្ម |
| ១១:១០-១២:០៥ | **ការសម្រេចបាននូវការត្រៀមខ្លួននាពេលអនាគត៖** បញ្ហាប្រឈម និងឱកាសសម្រាប់ឧស្សាហកម្មសំខាន់ៗរបស់កម្ពុជា។<br><br>សំណួរ-ចម្លើយ | Ken Loo, អគ្គលេខាធិការ, TAFTAC<br><br>Chi Q. Do, នាយកប្រតិបត្តិនៃគោលនយោបាយអាស៊ី, Responsible Business Alliance<br><br>Sophal Chhin, សហព័ន្ធស្វាយចន្ទីកម្ពុជា<br><br>Athit Kong, ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា( ស៊ីខៅឌូ ) |
| ១២:០៥-១២:១៥ | **សុន្ទរកថាបិទ** | Marc Beckmann, នាយកកម្មវិធីនៃGIZ FABRIC |

ចំណាំ៖ មានការប្រែសម្រួលជាខេមរភាសា និងភាសាអង់គ្លេសនៅក្នុងកម្មវិធី